ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

*ថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមីនា គ.ស. ២០២៥*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃកិច្ចប្រជុំ "ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"
## *លើកទី២៣ អាណត្តិទី១*

នាព្រឹកថ្ងៃទី១១ ខែមីនា គ.ស. ២០២៥, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. លើកទី២៣ អាណត្តិទី១ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយមានការចូលរួមពី ឯកឧត្តមអនុប្រធាន ឯកឧត្តម លោកជំទាវ និងលោក ដែលជាសមាជិក-សមាជិកា នៃក្រុមប្រឹក្សា អ.ស.ហ. ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម៖

**របៀបវារៈទី១. សេចក្តីព្រាងរបាយការណ៍សមិទ្ធផលឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

សេចក្តីព្រាងរបាយការណ៍សមិទ្ធផលឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ អ.ស.ហ. ត្រូវបានរៀបចំក្នុងគោលបំណងពិនិត្យលើសមិទ្ធផលដែល អ.ស.ហ. បានអនុវត្ត និងសម្រេចបានក្នុងឆ្នាំ២០២៤ ព្រមទាំងសម្រាប់ជាធាតុចូលក្នុងការកំណត់ភាពខ្លាំង និងភាពខ្សោយ ក្នុងការលើកទិសដៅការងារក្នុងឆ្នាំបន្ទាប់ សំដៅជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ ឆ្លងកាត់បទពិសោធន៍ប្រមាណ ៣ ឆ្នាំនៃការរៀបចំរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំរបស់ អ.ស.ហ. ដោយផ្សារភ្ជាប់ជាមួយនឹងយន្តការតាមដាន និងវាយតម្លៃ, ខ្លឹមសារនៃរបាយការណ៍សមិទ្ធផលឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ អ.ស.ហ. នេះ ត្រូវបានរៀបចំប្រកបដោយគុណភាព និងតម្លៃបន្ថែមខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ ឆ្លើយតបទៅនឹងការចង់បានរបស់ក្រុមប្រឹក្សា អ.ស.ហ. ។ សេចក្តីព្រាងរបាយការណ៍នេះត្រូវបានបែងចែកជា ៣ ផ្នែកធំៗ ពោលគឺ ផ្នែកទី១៖ សមិទ្ធផលឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ អ.ស.ហ. ជារួម, ផ្នែកទី២៖ សមិទ្ធផលឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទ អ.ស.ហ. និង ផ្នែកទី៣៖ តារាងម៉ាទ្រីកនៃសមិទ្ធផលឆ្នាំ២០២៤ របស់ អ.ស.ហ., ការងារក្រៅទិសដៅឆ្នាំ២០២៤ របស់ អ.ស.ហ. និងទិសដៅការងារឆ្នាំ២០២៥។

*ជាលទ្ធផល, ក្រុមប្រឹក្សា អ.ស.ហ. បានពិនិត្យ និងផ្តល់ការឯកភាពជាគោលការណ៍លើ សេចក្តីព្រាងរបាយការណ៍សមិទ្ធផលឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ អ.ស.ហ. ជាមួយ*



#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
Website: fsa.gov.kh, Telegram: t.me/fsacambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩០ ៧០០
Phone: (+855) 23 990 700
info@fsa.gov.kh

Khmer Law Association, www.khmerlaw.org

*នឹងការណែនាំឱ្យកែសម្រួលបន្ថែមទៅតាមអនុសាសន៍របស់អង្គប្រជុំដែលបានលើកឡើង និងសម្រេចមុននឹងដាក់ឆ្លងនីតិវិធីបន្ទាប់។*

**របៀបវារៈទី២.របាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ២០២៤ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

របាយការណ៍ត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៤ របស់ អ.ស.ហ. ត្រូវបានរៀបចំស្របតាមការចង្អុលបង្ហាញ និងការផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.** ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ប្រភពធនធានរបស់ អ.ស.ហ. នៅវដ្តថវិកាទាំងមូល។ របាយការណ៍នេះបានរួមបញ្ចូលនូវការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យវាយតម្លៃ ដើម្បីជំរុញការអនុវត្តឱ្យសម្រេចបានតាមផែនការដែលបានដាក់ចេញ។ ផ្អែកតាមលទ្ធផលនៃការបូកសរុបការអនុវត្តថវិកាប្រចាំឆ្នាំ២០២៤ បានបង្ហាញថា និយ័តករក្រោមឱវាទ អ.ស.ហ. បានខិតខំអនុវត្តការប្រមូលចំណូលទៅតាមអនុវិស័យរបស់ខ្លួន រហូតសម្រេចបានលទ្ធផលល្អប្រសើរ បើទោះបីជាស្ថានភាពសេដ្ឋកិច្ចស្ថិតនៅក្នុងភាពមិនច្បាស់លាស់។ ជាមួយគ្នានេះ, អង្គភាពក្រោមឱវាទ អ.ស.ហ. ក៏បានធ្វើវិចារណកម្មចំណាយរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ស្របតាមការកំណត់របស់រាជរដ្ឋាភិបាល។ ការណ៍នេះបានបង្ហាញឱ្យឃើញថា ការអនុវត្តថវិកាក្នុងក្របខណ្ឌ អ.ស.ហ. បាននិងកំពុងផ្លាស់ប្តូរកាន់តែប្រសើរឡើង ចាប់តាំងពីដំណាក់កាលរៀបចំថវិកា ការអនុវត្តថវិកា និងការតាមដានការអនុវត្តថវិកា ដើម្បីឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម។

*ជាលទ្ធផល, ក្រុមប្រឹក្សា អ.ស.ហ. បានកត់សម្គាល់ (Take-note) នូវរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ២០២៤ ព្រមទាំងណែនាំអង្គភាពក្រោមឱវាទ អ.ស.ហ. បន្តយកចិត្តទុកដាក់លើការងារពាក់ព័ន្ធ ក្នុងការជំរុញការអនុវត្តបន្ថែមទៀត ឱ្យសម្រេចលទ្ធផលតាមការគ្រោងទុក សម្រាប់ឆ្នាំ២០២៥។*

**របៀបវារៈទី៣. របាយការណ៍សិក្សាស្រាវជ្រាវស្តីពី "ប្រភេទហានិភ័យក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" របស់អគ្គលេខាធិការដ្ឋាន អ.ស.ហ.**

អគ្គលេខាធិការដ្ឋាន អ.ស.ហ. បានសិក្សា និងរៀបចំរបាយការណ៍សិក្សាស្រាវជ្រាវស្តីពី ប្រភេទហានិភ័យក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារនេះ មានគោលបំណងសិក្សាឱ្យបានស៊ីជម្រៅអំពីការកំណត់ និងការគ្រប់គ្រងហានិភ័យ សម្រាប់ជាគុណប្រយោជន៍ដល់ការតាមដាន និងការឃ្លាំមើលភាពធន់នៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលនឹងចូលរួមចំណែកដល់ការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងភាពជឿទុកចិត្តលើទីផ្សារ ស្របតាមបទប្បញ្ញត្តិជាធរមាន។ លទ្ធផលនៃការសិក្សាស្រាវជ្រាវបានកំណត់នូវសូចនាករវាស់វែងហានិភ័យ (KRIs) មួយចំនួនដែលនឹងអនុញ្ញាតឱ្យ អ.ស.ហ. គិតគូរបន្ថែមក្នុងការកំណត់នូវទិសដៅការងារបន្ទាប់សំខាន់ៗ រួមមាន៖ ១. រៀបចំក្របខណ្ឌគ្រប់គ្រងហានិភ័យ (RMF) ក្នុងក្របខណ្ឌ អ.ស.ហ., ២. ការរៀបចំម៉ូដែលឬទម្រង់នៃការវាយតម្លៃហានិភ័យលើសញ្ញាណនៃភាពងាយរងគ្រោះផ្នែកស្ថិរភាពហិរញ្ញវត្ថុ, ភាពតានតឹងនៅក្នុងទីផ្សារ និងអនុលោមភាពបទប្បញ្ញត្តិ ទាំងកម្រិតម៉ាក្រូ និងកម្រិតមីក្រូ, ៣. រៀបចំនិងគិតគូរម៉ូដែលវាយតម្លៃភាពតានតឹងហិរញ្ញវត្ថុ និងប្រព័ន្ធផ្តល់ដំណឹងហានិភ័យទុកជាមុន (EWS), ៤. តាមដានបញ្ហាឆ្លងវិស័យ និងបញ្ហាអន្តរវិស័យរវាងប្រព័ន្ធហិរញ្ញវត្ថុធនាគារ និងមិនមែនធនាគារ ព្រមទាំងបញ្ហាអន្តរវិស័យនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង ៥. ពង្រឹងការប្រមូលទិន្នន័យពាក់ព័ន្ធ ជាពិសេសទិន្នន័យបទប្បញ្ញត្តិ ទាំងទិន្នន័យគាំទ្រការវិភាគទីផ្សារ និងការវិភាគហានិភ័យ ប្រកបដោយសុក្រឹតភាព និងទាន់ពេលវេលា។



Khmer Law Association, www.khmerlaw.org

*ជាលទ្ធផល, ក្រុមប្រឹក្សា អ.ស.ហ. បានកត់សម្គាល់ (Take-note) នូវរបាយការណ៍ស្តីពីសិក្សាស្រាវជ្រាវស្តីពី "ប្រភេទហានិភ័យក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" ជាមួយនឹងការណែនាំបន្ថែមដល់អង្គភាពក្រោមឱវាទ អ.ស.ហ. ក្នុងការបន្តយកចិត្តទុកដាក់ និងជំរុញកិច្ចការនេះ។*

អង្គប្រជុំបានបិទបញ្ចប់សម័យប្រជុំលើកទី២៣ អាណត្តិទី១ នៅវេលាម៉ោង ១៣:០០ នាទីរសៀល ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**



Khmer Law Association, www.khmerlaw.org